ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ...០៤៥០........សនរប

# សេចក្តីជូនដំណឹង

## ស្តីពី

## ការធ្វើដំណើររបស់មន្ត្រី និងបុគ្គលិកផ្នែកសុខាភិបាលទាំងរដ្ឋ និងឯកជនដោយរួមទាំងផ្នែកឱសថស្ថាន ក្នុងអំឡុងពេលអនុវត្តវិធានការបិទខ្ទប់ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល

**យោង៖** -សេចក្តីសម្រេចលេខ៥៨ សសរ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបន្តការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

-សេចក្តីណែនាំលេខ០១ សណន ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីវិធានការលម្អិតដើម្បីរឹតបន្តឹងការអនុវត្តសេចក្តីសម្រេចស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

ដើម្បីសម្រួលដល់ការធ្វើដំណើររបស់មន្ត្រី បុគ្គលិកសុខាភិបាល និងឱសថស្ថានទាំងរដ្ឋ និងឯកជន ដែលត្រូវចេញ-ចូល ឆ្លងកាត់ទីតាំងភូមិសាស្ត្រដែលជាតំបន់បិទខ្ទប់ "តំបន់ក្រហម" និង "តំបន់លឿងទុំ" ស្របតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ក្រសួងសុខាភិបាល សូមធ្វើការណែនាំដូចខាងក្រោម៖

១-អង្គភាពសាធារណៈ រួមមាន មន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ វិទ្យាស្ថានជាតិ និងអង្គភាពថ្នាក់កណ្តាលប្រហាក់ប្រហែល ត្រូវរៀបចំលិខិតអនុញ្ញាតការធ្វើដំណើរជូនមន្ត្រីក្រោមឱវាទរបស់ខ្លួន ដែលមានតួនាទីចាប់ពីមន្ត្រី រហូតដល់អនុប្រធានអង្គភាព។

២-គ្រឹះស្ថានផលិតឱសថ គ្រឹះស្ថានផលិតសម្ភារ បរិក្ខារពេទ្យ គ្រឹះស្ថានអាហារ័ណ នីហារ័ណឱសថ ឱសថស្ថាន-ឱសថស្ថានរង និងម្ចាស់សេវាសុខាភិបាលឯកជន ត្រូវស្នើសុំការអនុញ្ញាតធ្វើដំណើររបស់បុគ្គលិកក្រោមឱវាទមក ក្រសួងសុខាភិបាល(អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ) ដោយភ្ជាប់ជាមួយអាជ្ញាប័ណ្ណ អាជីវកម្មមានសុពលភាព ស្រប



ទីស្តីការក្រសួងសុខាភិបាល ជិតផ្លូវលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

ច្បាប់ និងរៀបចំបញ្ជីឈ្មោះបុគ្គលិកក្នុងចំនួនអប្បបរមា ដែលត្រូវធ្វើដំណើរមកបំពេញការងារចេញ-ចូល ឆ្លងកាត់តំបន់ក្រហម និងតំបន់លឿងទុំ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដូចមានគំរូតារាងជូនភ្ជាប់។

៣- ការស្នើសុំបំពេញបែបបទ និងការផ្តល់លិខិតអនុញ្ញាតជូនអង្គភាព ឬ/និងក្រុមហ៊ុន ត្រូវធ្វើតាមប្រព័ន្ធអនឡាញដែលមានតំណរភ្ជាប់:https://t.me/joinchat/31xbPTHfDAc2MTA1។

ទទួលបានសេចក្តីជូនដំណឹងនេះ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រីប្រធានអង្គភាពថ្នាក់កណ្តាល ប្រធានគ្រឹះស្ថាន ម្ចាស់សេវាសុខាភិបាលឯកជន និងឱសថស្ថានទាំងអស់ជ្រាប និងចូលរួមអនុវត្តប្រកបដោយការទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម_ប៊ុនហេង**

លេខទំនាក់ទំនង:- ០១២ ៦៨៨ ១៨១
- ០១២ ៥៥១ ៦៦២